*Sin and the Fall*

Copyright © 2012 by The Gospel Coalition

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.
All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# បាប និងការធ្លាក់ចុះ

លោក រិតឌីត អេន្ឌ្រូ ៣ Reddit Andrews III

**មាតិកា**

ការដោះស្រាយបញ្ហារបស់មនុស្សជាតិ ........................................ 2
ការចូលមកនៃបាប ........................................ 4
បាបដំបូង និងការងាររបស់វា ........................................ 6
ដូច្នេះ តើយើងគួររស់នៅយ៉ាងណា? ........................................ 9
កំណត់ ........................................ 10

មានបញ្ហាកើតឡើងជាមួយនឹងមនុស្សជាតិនិងពិភពលោករបស់ពួកគេ។ មនុស្សគ្រប់សាសនានិងមនុស្សដែលគ្មានសាសនាទាំងអស់ក៏ទទួលស្គាល់សេចក្តីពិតនេះ។ ឧទាហរណ៍ នៅពេលមនុស្សជាតិនៅក្នុងសម័យទំនើប សំរេចបាននូវការរីកចំរើនយ៉ាងធំខាងបច្ចេកវិទ្យានិងវេជ្ជៈសាស្រ្ត នោះពួកគេក៏បានបង្កើតបញ្ហាជាច្រើនផងដែរ។ នៅក្នុងសតវត្សទី២០ មានមនុស្សប្រមាណ១៨៨លាននាក់បានស្លាប់ដោយសារសង្គ្រាម និងការកៀបសង្កត់[១] ហើយពួកគេជាច្រើនត្រូវបានរំលោភធ្វើឲ្យពិការ ឬធ្វើទារុណកម្មមុននឹងស្លាប់។ លោក គ្រីស្តូហ្វឺ រ៉ៃត Christopher Wright វាយការណ៍ថាៈ

> ពិភពលោកត្រូវភ័យរន្ធត់ដោយសារការវាយប្រហារលើអាគារភ្លោះរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោកក្នុងរដ្ឋញូយ៉ក នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ដែលមានមនុស្សជាងបីពាន់នាក់បានស្លាប់។ ជារៀងរាល់ថ្ងៃ ប្រជាជននៅទ្វីបអាប្រិករងទុក្ខស្មើនឹងពីរដងនៃព្រឹត្តិការណ៍៩/១១។ ព្យុះរលកសមុទ្រនៅក្នុងសមុទ្រឥណ្ឌាក្នុងខែធ្នូឆ្នាំ២០០៤ បានសំលាប់មនុស្សប្រហែល៣០០០០០នាក់ក្នុងរយៈពេលតែមួយថ្ងៃ។ នៅទ្វីបអាហ្វ្រិក ចំនួននៃអ្នកឆ្លងជំងឺអេដស៍ជារៀងរាល់ខែស្មើនឹងចំនួននៃអ្នករងគ្រោះនៃព្យុះរលកសមុទ្រនោះ។[២]

តើមានអ្វីខុសកើតឡើងជាមួយនឹងមនុស្សជាតិ?

## *ការដោះស្រាយបញ្ហារបស់មនុស្សជាតិ*

មនុស្សជាច្រើន រួមទាំងពួកអ្នកដឹកនាំខាងផ្នែកវិទ្យាសាស្រ្ត អប់រំ នយោបាយ និងសាសនា វិភាគបញ្ហារបស់មនុស្សដោយការសន្មត់ថា ទ្រឹស្តីនៃការវិវត្តន៏ធម្មជាតិគឺជាការពិត។ ទ្រឹស្តីនេះសន្និដ្ឋានថា ការអាក្រក់គឺជាផ្នែកនៃធម្មជាតិដើមពីប្រវត្តិសាស្រ្ត។ ឧទាហរណ៍ លោក ប៉ុល រីកឿ (Paul Ricoeur) ដែលជាទស្សនៈវិទូជនជាតិបារាំងបានសរសេរថាៈ

> យើងនឹងថាការអាក្រក់គឺជាផ្នែកនៃធម្មជាតិ...ដូច្នេះយើងត្រូវតែរួមបញ្ចូលការអាក្រក់ទៅក្នុងរឿងនៃសេចក្តីសង្ឃឹម។ តាមមធ្យោបាយមួយដែលយើងមិនដឹង ការអាក្រក់សហការ និងធ្វើការដើម្បីការរីកចំរើននគរព្រះ .....សេចក្តីជំនឿរាប់ជាសុចរិតមនុស្សដែលជឿថាការអាក្រក់ជាកត្តាមួយនៅក្នុងការអប់រំរបស់មនុស្សជាតិ។ សេចក្តី

ជំនឿមិនរាប់ជាសុចរិតនូវមនុស្សដែលមិនធ្លាប់មានជោគជ័យក្នុងការបែរចេញពីការដាក់ទោសមកឯសេចក្តីមេត្តាករុណានោះឡើយ។[៣]

ក្នុងគំនិតខ្លះ សាសនាអ៊ីស្លាមក៏មើលឃើញការអាក្រក់ជាផ្នែកធម្មជាតិ និងមិនអាចជៀសវាងបាននៃការរីកចំរើនរបស់មនុស្សផងដែរ។ គំនិតនេះត្រូវបានបញ្ជាក់ដោយលោក ណូម៉ានុល ហាក Nomanul Haq:

> មនុស្សជាតិចេញពីសួនច្បារគឺដូចជាកំណើតតាមធម្មជាតិ ទារកម្នាក់ប្រសូត្រចេញពីផ្ទៃរបស់ម្តាយ បក្សីចេញពីស៊ុត ឬត្រួយដុះពន្លកចេញពីមែក។ ដូចជាធម្មជាតិ អ័ដាមត្រូវតែវិវត្តខាងសីលធម៌ ព្រលឹងវិញ្ញាណ ប្រាជ្ញា ដូចជាទារករីកចំរើនទៅជាមនុស្សពេញវ័យ ហើយគ្រាប់ពូជរីកដុះជាដើមឈើខ្ពស់មួយ។[៤]

ដូច្នេះ យោងទៅតាមសាសនាអ៊ីស្លាម មនុស្សមិនចាំបាច់ត្រូវការសេចក្តីសង្គ្រោះពីការធ្លាក់ចុះដើម្បីយកបានមកវិញនូវលក្ខណៈដើមនៃសិរីល្អនោះទេ ប៉ុន្តែត្រូវការបំពេញសំរេចនូវកាតព្វកិច្ចមួយចំនួនដែលព្រះបានប្រទានឲ្យនៅក្នុងគម្ពីរគូរ៉ាន។

ប៉ុន្តែ ជំនឿគ្រីស្ទបរិស័ទវិភាគលើស្ថានការណ៍ដ៏លំបាករបស់មនុស្សជាតិខុសប្លែកពីគេ។ ជំនឿគ្រីស្ទបរិស័ទវិភាគលើការអាក្រក់ដោយការដាក់ការអាក្រក់នៅក្នុងផ្នែកពីរដែលទាក់ទងគ្នាទៅវិញទៅមក គឺអំពើបាប និងការធ្លាក់ចុះ។ ការអាក្រក់កើតមានដោយសារតែអំពើបាប ហើយអំពើបាបកើតមានដោយសារតែការធ្លាក់ចុះដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រដំបូងរបស់មនុស្សជាតិ។ នៅក្នុងតែងសេចក្តីដ៏អស្ចារ្យរបស់លោក យ៉ូណាថាន អេដវឺត Jonathan Edwards ស្តីអំពី បាបដើម គាត់សរសេរថា បាបរបស់អ័ដាមបាននាំការអាក្រក់មកក្នុងលោកិយៈ

> ខ្ញុំជឿថាគោលលិទ្ធិនេះគឺសំខាន់ណាស់ដែលគ្រប់គ្នានឹងយល់ស្រប បើ គោលលិទ្ធិនេះជាសេចក្តីពិត។ ពីព្រោះប្រសិនជាតាមធម្មជាតិមនុស្សទាំងអស់ស្ថិតក្នុងស្ថានភាពខូចទាំងស្រុង ដែលរួមមានទាំងការអាក្រក់នៅក្នុង និងការអាក្រក់ខាងក្រៅនោះដែលជាលទ្ធផល និងទណ្ឌកម្ម នោះយើងត្រូវតែទទួលយកសេចក្តីពិតនេះ គឺថា សេចក្តីសង្គ្រោះដ៏អស្ចារ្យរបស់យើង ព្រមទាំងសេចក្តីជំនឿពិត ឬការយល់ដឹងដ៏ត្រឹមត្រូវនូវដំណឹងល្អ ត្រូវតែបានសាងសង់លើសេចក្តីពិតនេះ។[៥]

លោក ប្លេស ប៉ាស្កាល់ Blaise Pascal សរសេរថាៈ

> វាជាការអស្ចារ្យណាស់ ដែលសេចក្តីអាថ៌កំបាំងដ៏ឆ្ងាយពីចំណេះដឹងរបស់យើង (សេចក្តីអាថ៌កំបាំងអំពីការរាលដាលរបស់បាប) គឺជាអ្វីដែលយើងត្រូវតែមាន ដើម្បីយើងអាចមានចំណេះដឹងអំពីខ្លួនយើងបាន!ពីព្រោះជាក់ស្តែងគ្មានអ្វីដែលធ្វើឲ្យយើងភ្ញាក់ផ្អើលជាងការដែលថា អំពើបាបរបស់មនុស្សដំបូងគឺជាហេតុនៃទោសសំរាប់អ្នកដទៃទៀតដែលនៅយ៉ាងឆ្ងាយពប្រភពនៃការរាលដាល (មនុស្សដំបូងនោះ) ដែលបាបបាបរបស់មនុស្សដំបូងនោះបានឆ្លងរាលដាលដល់មនុស្សផ្សេងទៀតតរៀងមក។ សំរាប់យើងរាល់គ្នា ការរាលដាលរបស់បាប មិនគ្រាន់តែហាក់ដូចជាមិនអាចកើតឡើងប៉ុណ្ណោះទេ តែវាហាក់ដូចជាអយុត្តិធម៌ណាស់ផងដែរ ពីព្រោះវាប្រឆាំងនឹងច្បាប់យុត្តិធម៌របស់យើងណាស់ដែលផ្តន្ទាទោសអស់កល្បនិច្ចលើក្មេងម្នាក់ដែលគ្មានសមត្ថភាពសំរេចចិត្តក្នុងការធ្វើបាបមួយគាត់ហាក់ដូចជាមានចំនែកតិចតួចបំផុត ហើយដែលត្រូវបានប្រព្រឹត្តតាំងពីប្រាំមួយពាន់ឆ្នាំមុនគាត់បានកើតមកម្លេះ។ គ្មានអ្វីធ្វើឲ្យយើងភ្ញាក់ផ្អើលជាងគោលលិទ្ធិបែបនេះទេ ប៉ុន្តែបើគ្មានសេចក្តីអាថ៌កំបាំង នេះទេ នោះយើងមិនអាចយល់ពីខ្លួនឯងបានឡើយ។[៦]

មានតែជំនឿគ្រីស្ទបរិស័ទទេដែលវិភាគលើស្ថានភាពលំបាករបស់មនុស្សបានត្រឹមត្រូវ។ ការអាក្រក់មាននៅដោយសារតែបាប ហើយបាបមាននៅដោយសារតែការធ្លាក់ចុះ។ ហើយបាបមិនមានដើមកំណើតនៅលើផែនដីនោះទេ ប៉ុន្តែនៅលើស្ថានសួគ៌តែម្តង។

បាបមិនបានកើតឡើងនៅលើផែនដីភ្លាមៗនោះទេ ប៉ុន្តែនៅលើស្ថានសួគ៌នៅក្នុងវត្តមានរបស់ព្រះ ហើយនៅជើងបល័ង្ករបស់ទ្រង់។ គំនិត បំណងប្រាថ្នា និងឆន្ទៈដែលរឹងទទឹងនឹងព្រះបានកើតឡើងជាដំបូងនៅក្នុងចិត្តរបស់ពួកទេវតា។[៧]

## *ការចូលមកនៃបាប*

«កាលដើមដំបូងឡើយព្រះបានបង្កើតផ្ទៃមេឃនិងផែនដី» (លោកុប្បត្តិ ១:១)។[៨] ពួកទេវតាបានឆ្លើយតបដោយចម្រៀងអំណរៈ «តើឫសផែនដីបានជាប់នៅលើអ្វី តើអ្នកណាបានបញ្ចុះថ្មជ្រុងនោះ ក្នុងកាលដែលផ្កាយព្រឹកបានច្រៀងជាមួយគ្នា ហើយអស់ទាំងកូនព្រះបានស្រែកអរសាទរ?» (យ៉ូប ៣៨:៦-៧)។ បន្ទាប់ពីបានបង្កើតចក្រវាឡទាំងមូល «ព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ» (លោកុប្បត្តិ ១:៣១)។ បន្ទាប់មកទៀតពួកទេវតាបានធ្វើបាបហើយត្រូវបានបោះចុះមកក្រោម (២ពេត្រុស ២:៤, យូដាស ៦)។ អ័ដាមដូចជាព្រះគ្រីស្ទ (រ៉ូម ៥:១២-១៩, ១កូរិនថូស ១៥:២២, ៤៥-៤៩) តំណាងឲ្យមនុស្សជាតិ។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បង្គាប់អ័ដាមថា ឯងនឹងស៊ីផ្លែឈើទាំងអស់ក្នុង សួនច្បារនេះបានតាមចិត្ត តែឯគ្រង់ដើមដឹងខុសត្រូវនោះមិនត្រូវឱ្យឯងស៊ីឡើយ ដ្បិតនៅថ្ងៃណា ដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន។ (លោកុប្បត្តិ ២:១៦-១៧)

បាបបានចូលមកក្នុងមនុស្សជាតិនៅពេលអ័ដាមនិងអេវ៉ាមិនបានស្តាប់បង្គាប់ព្រះហើយបរិភោគផ្លែឈើដែលព្រះហាមឃាត់។

> ដូច្នេះ ដែលបាបបានចូលមកក្នុងលោកិយ ដោយ សារមនុស្សតែម្នាក់ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្តីស្លាប់ បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ (ព្រោះរមែងមានបាបនៅ ក្នុងលោកិយ ដរាបដល់ក្រិត្យវិន័យ តែកាលមិនទាន់មាន ក្រិត្យវិន័យនៅឡើយ នោះមិនបានរាប់ជាទោសដល់គេ ទេ ប៉ុន្តែចាប់តាំងពីលោកអ័ដាម ដរាបដល់លោកម៉ូសេ នោះសេចក្តីស្លាប់បានសោយរាជ្យលើទាំងពួកអ្នកដែលធ្វើបាប មិនមែនដូចជាអំពើរំលងរបស់លោកអ័ដាមផង ដែលលោកជាគំរូពីព្រះអង្គដែលត្រូវយាងមក។ (រ៉ូម ៥:១២-១៤)

សាតាំងបានចូលទៅអ័ដាមតាមរយៈអេវ៉ាជាប្រពន្ធរបស់គាត់។

> កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្មម គួរនឹងចង់បាន ដើម្បីឱ្យបានប្រាជ្ញានោះនាងក៏យកបរិភោគ ព្រមទាំងចែក ឱ្យដល់ប្តីដែរ គាត់ក៏បរិភោគតាម នោះស្រាប់តែ ភ្នែករបស់អ្នកទាំង២បានភ្លឺឡើងហើយគេ ដឹងថាខ្លួននៅជាអាក្រាត (លោកុប្បត្តិ ៣:៦-៧ខ)

## សេចក្តីសុចរិតដំបូង

ព្រះបានបង្កើតអ័ដាមជាសុចរិត។ គាត់មានអ្វីដែលយើងអាចហៅថាសេចក្តីសុចរិតដំបូង។ នេះជាពេលវេលាពិសោធន៍មើលដែលអ័ដាមនិងអេវ៉ាត្រូវបានដាក់ឲ្យត្រូវសេចក្តីល្បួង ហើយអ្នកទាំងពីរបានចាញ់សេចក្តីល្បួងនោះ។ ពួកគេអាចមិនធ្វើបាប ហើយពួកគេក៏អាចធ្វើបាបបានដែរ ។

> ព្រះបានប្រទានសមត្ថភាពឲ្យមនុស្សអាចជ្រើសប្រឆាំងនឹងច្បាប់របស់ព្រះ។ តាមរយៈឆន្ទៈផ្ទាល់របស់ខ្លួន មិនមែនដោយការបង្ខិតបង្ខំពីខាងក្រៅទេ មនុស្សបានប្រើសមត្ថភាពនោះហើយបានធ្វើបាប។ ទោះនៅក្នុងលក្ខខ័ណ្ឌសាច់ឈាម ឬក្នុងលក្ខណៈសីលធម៌ ឬក្នុងបរិស្ថានរបស់គាត មនុស្សមិនខ្វះអ្វីសោះដែលបណ្តាលឲ្យគាត់

ធ្វើបាប។ វាជាជម្រើសដោយសេរីនៅក្នុងគាត់ ។ លោក ឡេតឡូ Laidlaw បានសរសេរថា “បាបលេចចេញមកពីសំណួមពរខាងក្រៅ និងឱកាសខាងក្រៅ ប៉ុន្តែវាជាវិបត្តិខាងក្នុង”។[៩]

សេចក្តីល្បួងរបស់អ័ដាមមិនបានមានន័យថាគាត់បានមានកំហុសនោះទេ ប៉ុន្តែការចុះចាញ់របស់គាត់ជារឿងមិនសមហេតុសមផល។ ព្រះបានប្រទានពរឲ្យអ័ដាមមានអំណាចគ្រប់គ្រងលើផែនដី មានប្រពន្ធដែលដូចជាគាត់ ហើយនិងទំនាក់ទំនងជាមួយព្រះអម្ចាស់ផ្ទាល់។ ព្រះដាក់របស់សព្វសារពើរក្រោមការគ្រប់គ្រងរបស់អ័ដាម លើកលែងតែដើមឈើមួយដើម ។ គុណប្រយោជន៏របស់ព្រះគឺធំធេង ហើយការព្រមានសំរាប់ការហូបផ្លែឈើហាមឃាត់ក៏ធំធេងផងដែរ។

## ការអាក្រក់ និងបំណងព្រះឫទ័យរបស់ព្រះ

ព្រះបានកំណត់ដោយអធិបតីភាពថា បាបនឹងចូលមកក្នុងលោកិយ ហើយអ័ដាមទទួលខុសត្រូវចំពោះការធ្វើបាបដោយសេរីនេះ។

> ព្រះទ្រង់បានធ្វើការកំណត់ទុកជាមុនដោយសេរី និងមិនផ្លាស់ប្តូរតាំងពីអស់កាល្ប ប្រកបដោយព្រះប្រាញាណបំផុតនិងព្រះតម្រិះដ៏បរិសុទ្ធនៃព្រះហឫទ័យទ្រង់ នូវអ្វីៗដែលនឹងកើតឡើង ប៉ុន្តែទោះបើដោយហេតុនោះក្តី ទ្រង់មិនមែនជាអ្នកបង្កើតអំពើបាប ឬជាអ្នកបំពានលើឆន្ទៈរបស់ស្នាព្រះហស្ថទាំងឡាយ ក៏មិនបានដកចេញនូវសេរីភាព ឬយថាភាពនៃហេតុទីពីរនោះដែរ ផ្ទុយទៅវិញទ្រង់បង្កើតពួកវាឡើង។ (សេចក្តីថ្លែងការណ៍អំពីសេចក្តីជំនឿនៅវ៉េស្ទមិនស្ទើរ ៣.១)

មនុស្សជាច្រើនសួរសំនួរថា តើព្រះមានភាពវៃឆ្លាតនិងយុត្តិធម៌ឬទេក្នុងការធ្វើឲ្យមានការអាក្រក់? ព្រះដែលបរិសុទ្ធនិងមិនមែនជាអ្នកបង្កើតការអាក្រក់ ទ្រង់មិនគ្រាន់ត្រឹមតែ «អនុញ្ញាត» ឲ្យមានការអាក្រក់ប៉ុណ្ណោះនោះទេ។ វាមិនមែនជាការពិតទេដែលថា ព្រះមិនបានតាំងឲ្យមានការអាក្រក់ទេ ប៉ុន្តែបានអនុញ្ញាតឲ្យវាកើតឡើង។ ទស្សនៈដែលថាព្រះគ្រាន់តែអនុញ្ញាតឲ្យមានការអាក្រក់មិនមែនជាទស្សនៈដែលផ្តល់ចំលើយដែលដកយកចេញនូវភាពតានតឹងដែលមកពីការបញ្ជាក់អះអាងថាព្រះកំណត់ឲ្យមានការអាក្រក់នោះទេ ពីព្រោះនៅក្នុងករណីទាំងពីរព្រះកំពុងរៀបចំការចូលមករបស់ បាប។ លោក បាវីន្គ (Bavinck) សង្កេតឃើញថាៈ

> ព្រះមិនបានភ័យខ្លាចចំពោះការមាននៅនិងអំណាចរបស់ បាបនិងការអាក្រក់នោះទេ។ ទ្រង់ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ដើម្បីតាមរយៈ បាបនិងការអាក្រក់និងការប្រឆាំងនឹងវា នោះទ្រង់នឹងបើកសំដែងលក្ខណៈសម្បត្តិជាព្រះរបស់ទ្រង់។ ប្រសិនបើទ្រង់មិនបានអនុញ្ញាតឲ្យ បាបនិងការអាក្រក់មាននៅទេ នោះយើងមិនអាចជឿបានថា ក្នុងគ្រប់លក្ខណៈសម្បត្តិទាំងអស់របស់ទ្រង់ ព្រះអម្ចាស់ខ្ពស់លើសអំណាចទាំងអស់នៅក្នុងការបង្កបង្កើតនោះឡើយ។ ព្រោះស្នាព្រះហស្តដែលមានហេតុផលទាំងអស់ជាស្នាព្រះហស្ត ដែលមានដែនកំណត់និងអាចផ្លាស់ប្តូរបាន មានលទ្ធភាពបោះបង់ចោលសេចក្តីជំនឿបាន។ ប៉ុន្តែដោយសារទ្រង់ជាព្រះ នោះទ្រង់មិនដែលខ្លាចផ្លូវនៃសេរីភាព ឬ បាប ឬការផ្ទុះឡើងនៃសេចក្តីអាក្រក់ ឬអំណាចរបស់សាតាំងសោះឡើយ។ ដូច្នេះ ព្រះតែងតែគ្រប់គ្រងលើបាបជានិច្ច ទោះទាំងដើមកំណើតនិងការវិវត្តន៏របស់វា ។ ទ្រង់មិនបង្ខំបាប ឬបង្ខាំងវាដោយហឹង្សានោះទេ ប៉ុន្តែទ្រង់បណ្តោយឲ្យវាឈានដល់កំលាំងពេញលេញរបស់វា។ ទ្រង់នៅតែជាស្តេច ប៉ុន្តែទ្រង់អនុញ្ញាតឲ្យមានបាបនៅក្នុងនគររបស់ទ្រង់។ ទ្រង់អនុញ្ញាតឲ្យវាមានអ្វីៗទាំងអស់ លោកិយរបស់ទ្រង់ ស្នាព្រះហស្តរបស់ទ្រង់ និងសូម្បីតែអង្គដែលទ្រង់បានចាក់ប្រេងតាំងក៏ដោយ ពីព្រោះការអាក្រក់មិនអាចមាននៅដោយគ្មានការល្អបាននោះទេ។ ព្រះដ៏ជាស្តេចលើសអស់ទាំងស្តេច ទ្រង់អនុញ្ញាតឲ្យ បាបប្រើអ្វីទាំងអស់ដែលជារបស់ទ្រង់ ផ្តល់ឱកាសឲ្យបាបបង្ហាញអ្វីដែលវាអាចធ្វើបាន គឺដើម្បីនៅចុងបញ្ចប់ បាបនឹងចាកចេញពីចំបាំង។ ពីព្រោះ បាបបំផ្លាញខ្លួនឯងដោយ

សេរីភាពដែលព្រះបានផ្ដល់ឲ្យវា គឺវាស្លាប់ដោយសារជំងឺរបស់វា វា ជាអ្នកធ្វើឲ្យខ្លួនឯងស្លាប់។ នៅចំនុចកំពូលនៃអំណាចរបស់បាបគឺការឆ្កាងព្រះគ្រីស្ទ បាបត្រូវបានបើកសំដែងជាសាធារណៈថាគ្មានអំណាច (កូល៉ុស ២:១៥)។[១០]

## *បាបដំបូង និងការផ្សាររបស់វា*

លទ្ធផលនៃបាបរបស់អ័ដាមគឺធ្ងន់ធ្ងរណាស់។ ហើយលទ្ធផលទាំងនោះជះឥទ្ធិពលមកលើយើងម្នាក់ៗ។

### បាបគឺជាការទទឹងច្បាប់ដែលនាំមកនូវការជំនុំជំរះ។

បាបគឺជាការល្មើសនឹងច្បាប់របស់ព្រះដ៏ជាស្ដេចនៃស្ថានសួគ៌និងផែនដី។

> អស់អ្នកណាដែលប្រព្រឹត្តអំពើបាប នោះគឺជាអ្នកប្រព្រឹត្តរំលងក្រិត្យវិន័យ។ អំពើបាបជាការរំលងក្រិត្យវិន័យ (១យ៉ូហាន ៣:៤)។

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បង្គាប់អ័ដាមថា ឯងនឹងស៊ីផ្លែឈើទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឱ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណា ដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន។ (លោកុប្បត្តិ ២:១៦-១៧)

ជាការឆ្លើយតបទៅនឹងការបះបោររបស់អ័ដាម ព្រះបានដាក់បណ្ដាសារទាំងមនុស្សជាតិនិងពិភពលោករបស់ពួកគេ (លោកុប្បត្តិ ៣:១៦-១៩)។ លទ្ធផលគឺជាការស្លាប់ខាងសាច់ឈាមនិងព្រលឹងវិញ្ញាណ។ ហើយដោយមានគោលដៅប្រោសលោះលោកិយ ព្រះបានដាក់បណ្ដាសារពិភពលោកថាៈ «ពីព្រោះជីវិតទាំងឡាយបានត្រូវចុះចូលនឹងសេចក្ដីឥតប្រយោជន៍ តែមិនមែនដោយស្ម័គ្រពីចិត្ត គឺដោយព្រោះព្រះអង្គ ដែលទ្រង់បានបញ្ចុះបញ្ចូលវិញ ដោយសង្ឃឹមថា ជីវិតទាំងនោះឯងនឹងបានរួចពីចំណងនៃសេចក្ដីពុករលួយ ឲ្យបានសេរីភាពនៃសិរីល្អរបស់ពួកកូនព្រះវិញ» (រ៉ូម ៨:២០-២១)។ ការនេះពន្យល់អំពីការអាក្រក់របស់ធម្មជាតិ ពីព្រោះប្រសិនបើមនុស្សមិនបានបះបោរនិងធ្លាក់ចុះនោះទេ នោះនឹងមិនមានការរញ្ជួយដី ខ្យល់គួច ទឹកជំនន់ ឬខ្យល់ព្យុះនោះដែរ។

### លទ្ធផលរបស់បាបគឺជាការដាច់ចេញពីព្រះ

អំពើបាបរបស់អ័ដាមបានបំបែកទំនាក់ទំនងរវាងគាត់នឹងព្រះ។ បាបរបស់មនុស្សម្នាក់ហាក់ដូចជាមិនសំខាន់ចំពោះមនុស្សជាតិទេ ប៉ុន្តែវាសំខាន់ចំពោះព្រះដ៏បរិសុទ្ធដែល «មានព្រះនេត្របរិសុទ្ធក្រៃលែង នឹងទតមើលការអាក្រក់មិនបាន ក៏នឹងពិនិត្យមើលការទុច្ចរតមិនបានដែរ» (ហាបាគុក ១:១៣)។ ដូច្នេះព្រះ «បានបណ្ដេញមនុស្សចេញ ហើយដាក់ចេរូប៊ីននៅខាងកើតសួនច្បារអេដែន នឹងដាវដែលជាអណ្ដាតភ្លើងរេបែរទៅគ្រប់ទិស ដើម្បីរក្សាផ្លូវទៅឯដើមជីវិត» (លោកុប្បត្តិ ៣:២៤)។

មនុស្សគឺជាពួកខ្មាំងសត្រូវរបស់ព្រះ ប៉ុន្តែនៅពេលព្រះយេស៊ូវសង្គ្រោះមនុស្សជាតិ នោះទ្រង់ផ្សះផ្សាពួកគេជាមួយនឹងព្រះឡើងវិញ «គឺពីដំណើរដែលព្រះទ្រង់គង់ក្នុងព្រះគ្រីស្ទ កំពុងផ្សះផ្សាលោកិយនឹងព្រះអង្គទ្រង់ ឥតប្រកាន់ទោសគេទៀត ហើយទ្រង់បានប្រគល់ព្រះបន្ទូល ពីការផ្សះផ្សានោះមកយើងខ្ញុំ។» (២កូរិនថូស ៥:១៩) «ដ្បិតកាលយើងជាខ្មាំងសត្រូវ បើយើងបានជាមេត្រីនឹងព្រះវិញទៅហើយ ដោយព្រះរាជបុត្រាទ្រង់សុគត ដូច្នេះ ដែលយើងបានជាមេត្រីហើយ នោះប្រាកដជាយើងនឹងបានសង្គ្រោះជាមិនខានលើសទៅទៀត ដោយទ្រង់មានព្រះជន្មរស់ឡើងវិញ» (រ៉ូម ៥:១០)។

### បាបមានលក្ខណៈជាសកល

> ដូច្នេះ ដែលបាបបានចូលមកក្នុងលោកិយ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ...ដូច្នេះ ដែលមនុស្សទាំងអស់ត្រូវទោសដោយព្រោះអំពើរំលងតែ១ នោះមនុស្ស

ទាំងអស់ក៏បានរាប់ជាសុចរិតឱ្យបានជីវិតវិញ ដោយសារអំពើសុចរិតតែ១បែបដូច្នោះដែរ ដ្បិតដូចជាមនុស្ស ជាច្រើន បានត្រឡប់ជាមានបាប ដោយសារមនុស្សតែម្នាក់ មិនបានស្តាប់បង្គាប់ជាយ៉ាងណា នោះមនុស្សជាច្រើន ក៏បានត្រឡប់ជាសុចរិតដោយសារម្នាក់បានស្តាប់បង្គាប់វិញយ៉ាងនោះដែរ។ (រ៉ូម ៥:១២,១៨-១៩)

ដ្បិតដែលសេចក្តីស្លាប់បានមកដោយសារមនុស្ស នោះសេចក្តីដែលមនុស្សស្លាប់បានរស់ឡើងវិញ ក៏មក ដោយសារមនុស្សដែរ ព្រោះ ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏ នឹងបានប្រោសឱ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ (១កូរិនថូស ១៥:២១-២២)។

ទាំងព្រះគ្រីស្ទនិងអ័ដាមមានតួនាទីជាអ្នកតំណាង

ពួកគ្រីស្ទបរិស័ទយល់ឃើញខុសៗពីគ្នាអំពីរបៀបដែលទោសនិងភាពខូចរបស់អ័ដាមត្រូវបានរាលដាលដល់មនុស្ស ទាំងអស់។ អ្នកខ្លះគិតថាយើងមិនអាចដឹងបានទេ។ អ្នកផ្សេងទៀតជឿថា អ័ដាមជាប់ទាក់ទងនឹងមនុស្សជាតិទាំងអស់ គឺ មនុស្សទាំងអស់នៅក្នុងអ័ដាមនៅពេលគាត់បានធ្វើបាប (សូមមើល ហេព្រើរ ៧:៩-១០)។ ទស្សនៈដែលថាអ័ដាមគឺជាអ្នក តំណាងអោយមនុស្សជាតិទាំងមូល គួរសមហេតុផលច្រើនជាង។[11] អំពើបាបរបស់គាត់ត្រូវបានបញ្ចូលមកក្នុងពូជពង្ស ទាំងអស់របស់គាត់។

## បាបគឺជាសេចក្តីពុករលួយ

បាបចាក់ទម្លុះគ្រប់កន្លែងនិងធ្វើឲ្យមនុស្សពុករលួយទាំងស្រុង។ មនុស្សខ្លះហៅការនេះថា «សេចក្តីពុករលួយទាំងស្រុង » ដែលជាពាក្យមួយងាយនឹងយល់ច្រឡំ។ វាមិនមានន័យថាមនុស្សគ្រលប់ជាអាក្រក់ទាំងស្រុង ហើយមិនអាចធ្វើការល្អ ណាបានសោះនោះទេ។ វាមានន័យថា បាបជះឥទ្ធិពលលើមនុស្សម្នាក់ទាំងមូល «គ្រប់មនុស្សជាតិទាំងអស់ត្រូវដាច់ចេញពី ព្រះ មានសេចក្តីពុករលួយក្នុងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេ (ឧទាហរណ៍ ខាងសាច់ឈាម ខាងផ្លូវចិត្ត ខាងឆន្ទៈ ខាងអារម្មណ៍ និងខាងព្រលឹងវិញ្ញាណ»។[12]

នៅពេលអ័ដាមនិងអេវ៉ាបានធ្វើបាប រំពេចនោះពួកគេបានមានភាពខ្មាស់អៀននិងប៉ុនប៉ងបិទបាំងភាពអាក្រាតរបស់ ពួកគេ។ ពួកគេក៏មានអារម្មណ៍ណ៍ថាខ្លួនមានទោស ដូច្នេះពួកគេក៏បានពួន។ ពីមុនមក ពួកគេមិនដែលមានអារម្មណ៍ណ៍ ដូចនេះទ ប៉ុន្តែឥឡូវពួកគេនឹងមិនអាចយកទោស សេចក្តីខ្មាស់ និងសេចក្តីពុករលួយចេញពីខ្លួនរបស់ពួកគេបានទេ (សូម មើលលោកុប្បត្តិ ៣:៨-១៣)។ សាតាំងបានសន្យាថា ពួកគេនឹងមានចំណេះដឹងអំពីការល្អនិងការអាក្រក់ ប៉ុន្តែសាតាំងមិន បានប្រាប់ពួកគេអំពីលទ្ធផលឡើយ។ លោក បាវីន្ក (Bavink) សរសេរថា:

> យោងទៅតាមវិទ្យាសាស្រ្តសម័យទំនើប ជំងឺមិនមែនជាសារធាតុមួយនោះទេ ប៉ុន្តែជាការរស់នៅក្នុងស្ថានភាព ផ្លាស់ប្តូរ តាមរបៀបនេះដែលសរីរាង្គនិងតួនាទីរបស់ជីវិតនោះត្រូវបានរំខាននៅក្នុងសកម្មភាពធម្មតារបស់ពួកគេ។ ដូចគំនិតដែរ បាបមិនមែនជាសារធាតុមួយទេ ប៉ុន្តែជាការប្រើខុសនូវគ្រប់ទាំងអំណោយទាននិងថាមពលដែល ព្រះអង្គប្រទានឲ្យមនុស្ស ដែលវាធ្វើឲ្យមនុស្សធ្វើការតាមទិសដៅមួយផ្សេងដែលមិនឆ្ពោះទៅរកព្រះទេ គឺចេញឆ្ងាយ ពីទ្រង់វិញ។ ទាំងហេតុផល ឆន្ទ: ចំណាប់អារម្មណ៍ណ៍ អារម្មណ៍ណ៍ តណ្ហា សមត្ថភាពផ្លូវចិត្តនិងរូបកាយ ដែលធ្លាប់ បានប្រើដើម្បីគោលបំណងសុចរិត ប៉ុន្តែឥឡូវ តាមរយៈអំពើបាប ត្រូវបានប្រើដើម្បីគោលបំណងទុច្ចរិតវិញ។ រូបភា ពនៃព្រះដែលមនុស្សបានទទួលនៅពេលដែលព្រះបង្កើតខ្លួន មិនមែនជាសារធាតុមួយទេ ប៉ុន្តែវាជាផ្នែកនៃលក្ខណៈ របស់មនុស្ស ដូច្នេះការបាត់បង់រូបភាពដើមនោះ នាំឲ្យមនុស្សត្រឡប់ជាខូចរូបរាង។[13]

«ឯចិត្តជាគ្រឿងបញ្ឆោតលើសជាងទាំងអស់ ហើយក៏ អាក្រក់ហួសល្បត់ផង តើអ្នកណានឹងអាចស្គាល់បាន» (យេរេមា ១៧:៩)។ «គំនិតគេត្រូវបង្អាប់ ហើយគេដាច់ចេញពីព្រះជន្មព្រះ ដោយសារសេចក្តីខ្លៅល្ងង់ក្នុងខ្លួនគេ ព្រោះចិត្តគេរឹងទទឹង» (អេភេសូរ ៤:១៨)។

លោក ដែបនី (Dabney) ពន្យល់ថាៈ

> សីលធម៌ដែលមានបាបរបស់យើងស្ថិតនៅក្នុងទំនោរខាងសីលធម៌។ ប៉ុន្តែដោយព្រោះទំនោរខាងសីលធម៌របស់យើងគ្រប់គ្រងលើសមត្ថភាពឥន្ទ្រិយទាំងឡាយ និងលើផ្នែកផ្សេងៗនៃព្រលឹងនិងរូបកាយរបស់យើង នោះសកម្មភាពទាំងអស់ដែលពាក់ព័ន្ធនឹងសីលធម៌ត្រូវបានបង្ខូចខាងសីលធម៌។ បញ្ញាចិត្តមិនត្រូវបានបំផ្លាញទេ ប៉ុន្តែវាត្រូវទទួលឥទ្ធិពលយ៉ាងខ្លាំងពីសេចក្តីប៉ងប្រាថ្នាអាក្រក់ ហើយមនោសញ្ចេតនាខាងសិលធម៌ដែលជាសភាវះពីកំណើតរបស់យើង ដែលគួរតែមកជាមួយជំរើសពេញដោយបាបរបស់យើង ហើយព្រមានយើងទាស់នឹងបាបត្រូវបានទៅជាខ្សោយ ឬក៏ស្លាប់តែម្តង។ ការយល់ដឹងរបស់យើងទាក់ទងនឹងប្រធានបទសីលធម៌ទាំងអស់ត្រូវបានបង្ខូចដោយការលំអៀងនៃចិត្ត ដែលនាំឲ្យយើងហៅល្អថាអាក្រក់ ហើយអាក្រក់ថាល្អ។ ដូច្នេះ ការនេះផ្តល់ឲ្យមាន "ភាពងងឹត(ឬការខ្វាក់)នៃគំនិត" ចំពោះប្រធានបទសីលធម៌ទាំងអស់។ សតិរបស់យើងរក្សាទុកនូវរូបភាព និងការចងចាំដែលពុករលួយ ហើយការនេះក៏ជះឥទ្ធិពលបន្តដល់ ការស្រមើស្រមៃរបស់យើង។ ទាំងសតិ និងការស្រមើស្រមៃក៏ត្រលប់ទៅជាខូច ទាំងពីរ។ បំណងប្រាថ្នាខាងសាច់ឈាម ដែលត្រូវបានជំរុញដោយតណ្ហា ដោយសតិឬការស្រមើស្រមៃដែលខូច និងដោយការចង់តំរូវចិត្តហួសហេតុរបស់យើង បានត្រលប់ជាផ្តាច់ការហួសហេតុ។ រូបកាយ និងឥន្ទ្រិយរបស់យើងត្រូវបានត្រលប់ជាអ្នកបំរើរបស់សេចក្តីទុច្ចរិត។ ដូច្នេះ អ្វីដែលព្រះអង្គបង្កើតដើម្បីគោលបំណងបរិសុទ្ធត្រូវបានប្រើសំរាប់គោលបំណងមិនបរិសុទ្ធវិញ។[១៤]

## បាបបណ្តាលឲ្យមានអសមត្ថភាព

លក្ខខ័ណ្ឌរបស់មនុស្សទាំងអស់គឺពុករលួយទាំងស្រុង។ ជាលទ្ធផលគឺមនុស្សមានអសមត្ថភាពទាំងស្រុងៈ បើសិនជាគ្មានអន្តរាគមន៍ដែលពេញដោយព្រះគុណរបស់ព្រះផ្ទាល់ទេ មនុស្សមិនអាចដោះស្រាយលក្ខខ័ណ្ឌរបស់គេបានឡើយ។ លោក ដែបនី Dabney ពន្យល់ថាៈ

> សកម្មភាពខាងសីលធម៌និមួយៗអាចបង្កើនទំនោររបស់យើងទៅចំពោះសកម្មភាពនោះ។ តើអ្នកគិតថាទំនោរដែលបង្កើតឡើងដោយសកម្មភាពមួយគឺតូចដែរទេ? មិនមែនជានិច្ចកាលនោះទេ។ កំលាំងជំរុញចំពោះ បាបនឹងកើនឡើង តែពេលខ្លះវាកើន ឡើងបន្តិចម្តងៗ ។ ពេលនេះ ការស្រលាញ់ខ្លួនឯងបានក្លាយជាគោលការណ៍នៃសកម្មភាព ហើយវានឹងបន្តពង្រឹងអំណាចរបស់វា។ បាបដំបូងបង្អស់ បង្កើតទំនោរមួយដើម្បីបង្កើនសេចក្តីពុករលួយរហូតដល់សេចក្តីពុករលួយពេញលេញ ហើយវាជាសេចក្តីស្លាប់ខាងព្រលឹងវិញ្ញាណ។ លទ្ធផលនៃសេចក្តីស្លាប់ខាងសាច់ឈាមគឺ ជាសាកសពដែលអាចចុះស្គមបន្តិច នៅក្តៅឧណ្ហៗ វាអាចនៅមានស្នាមពណ៌នៅលើថ្ពាល់ហើយស្នាមញញឹមនៅលើបបូរមាត់ វាអាចនៅមានតំលៃហើយស្អាតចំពោះអស់អ្នកដែលបានស្រលាញ់អ្នកនោះ។ ប៉ុន្តែវាបានស្លាប់ទៅហើយ ហើយដំណើរស្អុយរលួយយ៉ាងអាក្រក់ក៏មកដល់។[១៥]

នេះមិនមែនមានន័យថា មនុស្សចង់ចុះចូលចំពោះព្រះ តែមិនអាច នោះទេ។ ឆន្ទៈរបស់មនុស្សត្រូវពុករលួយដែលបណ្តាលឲ្យ ពួកគេមិនចង់ធ្វើអ្វីដែលត្រឹមត្រូវ។ «ព្រោះគំនិតខាងសាច់ឈាមនោះរមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង» (រ៉ូម ៨:៧)។ មនុស្សបន្តរឹងទទឹងនឹងព្រះដែលពិតជាអ្វីពួកគេចង់ធ្វើ រហូតដល់ព្រះផ្លាស់ប្តូរឆន្ទៈរបស់ពួកគេដើម្បីឲ្យពួកគេចង់ចុះចូលចំពោះព្រះវិញ។

បាបបណ្ដាលឲ្យជាប់ក្នុងចំណងរបស់សាតាំង

នៅពេលអ័ដាមបានធ្វើបាប នោះអំណាចគ្រប់គ្រងផែនដីត្រូវបានផ្ទេរពីអ័ដាមទៅឲ្យសាតាំង។ សាតាំងដឹកនាំកំលាំងវិញ្ញាណអាក្រក់ដ៏ធំ ដ៏មានអំណាចប្រឆាំងនឹងព្រះ ហើយប្ដេជ្ញា បំផ្លិចបំផ្លាញប្រជារាស្ត្ររបស់ព្រះ។ សាតាំងចោទប្រកាន់និងល្បួងមនុស្ស (សូមមើល យ៉ូប ១, ១វបាក្សត្រ ២១:១, សាការី ៣)។

ឈ្មោះសាតាំងមានន័យថា «ខ្មាំងសត្រូវ»។ វាក៏ត្រូវបានហៅថា អារក្ស (អង់គ្លេស Devil មានន័យថា «អ្នកនិយាយបង្កាច់») មេកំណាច អ្នកចោទប្រកាន់ មេល្បួង អារក្សបេលាល (ដែលមានន័យថា «ភាពគ្មានតំលៃ») បេលសេប៊ូល (ឈ្មោះរបស់ព្រះរុយនៅអេក្រុន) មេគ្រប់គ្រងលើវិញ្ញាណអាក្រក់ មេគ្រប់គ្រងរាជ្យលើអាកាស ចៅហ្វាយរបស់លោកិយនេះ ព្រះរបស់លោកិយនេះ នាគដ៏ធំ និងសត្វពស់ពីបុរាណ។ វាគឺជាព្រះរបស់លោកិយនេះដែលធ្វើឲ្យគំនិតរបស់អ្នកមិនជឿងងឹតរហូតទាល់តែ ព្រះបញ្ចាំងបន្លឺសេរីភាពរបស់ព្រះគ្រីស្ទទៅក្នុងចិត្តរបស់ពួកគេ (២កូរិនថូស ៤:១-៦)។ «លោកិយទាំងមូលដេកនៅក្នុងឱវាទនៃមេកំណាចវិញ» (១យ៉ូហាន ៥:១៩)។ នេះជាហេតុនាំឲ្យប៉ុលសរសេរថា:

> ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ ជាការដែលអ្នករាល់គ្នាបានប្រព្រឹត្ត តាមរបៀបលោកីយនេះ គឺតាមមេគ្រប់គ្រងរាជ្យលើអាកាស ជាវិញ្ញាណដែលសព្វថ្ងៃនេះបណ្ដាលមកក្នុងពួកមនុស្សរឹងចចេស យើងរាល់គ្នាទាំងអស់ក៏បានប្រព្រឹត្តក្នុងពួកនោះពីដើមដែរ ដោយសេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមយើងទាំងប្រព្រឹត្តសេចក្ដីដែលសាច់ឈាម និងគំនិតយើងចង់បានផង ហើយតាមកំណើតយើង នោះយើងជាមនុស្សជាប់ក្នុងសេចក្ដីខ្ញាល់ ដូចជាមនុស្សឯទៀតដែរ (អេភេសូរ ២:១-៣)។

លោក បាវីន្គ (Bavinck) សរសេរថា:

> មានអំពើបាបផ្ទាល់ខ្លួនម្នាក់ៗ ប៉ុន្តែក៏មានអំពើបាបសង្គមរួមគ្នា អំពើបាបរបស់ក្រុមគ្រួសារ របស់ជាតិសាសន៍។ល។... យើងគ្រាន់តែកត់សំគាល់ផ្នែកដ៏តូចមួយនៃអំពើបាបរបស់យើង ហើយយើងគ្រាន់តែកត់សំគាល់សើៗប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើយើងអាចចាក់ទំលុះកាយវិការខាងក្រៅ ហើយឃើញឫសអំពើបាបនៅក្នុងចិត្តរបស់មនុស្ស នោះយើងប្រហែលនឹងសន្និដ្ឋានថា នៅក្នុងបាបមានគំនិត ផែនការ គំរូខ្នាត ឬយើងអាចនិយាយម៉្យាងទៀតបានថានៅក្នុង បាបមានប្រព័ន្ធ...បាបប្រឆាំងនឹងព្រះ ទោះទាំងគោលការណ៍ទូទៅ និងមូលដ្ឋានគ្រឹះ។ បំណងរបស់វានៅក្នុងលោកិយគឺអំណាចគ្រប់គ្រងដោយអធិបតេយ្យ ហើយគ្រប់ទាំងអំពើបាបនិមួយៗ សូម្បីតែតូចបំផុតដែលជាការរំលងនឹងក្រឹត្យវិន័យរបស់ព្រះ បំរើគោលដៅចុងក្រោយនេះ ក្នុងការភ្ជាប់ទំនាក់ទំនងជាមួយប្រព័ន្ធទាំងមូល។ ប្រវត្តិសាស្ត្រពិភពលោកមិនមែនជាដំណើរការទៅមុខនៃការវិវត្តន៍ដែលគ្មានទិសដៅនោះទេ តែគឺជាជំលោះខាងវិញ្ញាណដែលបានកំពុងកើតឡើងអស់រយៈពេលជាច្រើនសតវត្ស ជាសង្គ្រាមរវាងវិញ្ញាណខាងលើនិងវិញ្ញាណខាងក្រោម រវាងព្រះគ្រីស្ទនិងអាទទឹងព្រះគ្រីស្ទ រវាងព្រះនិងសាតាំង។[១៦]

## *ដូច្នេះ តើយើងគួររស់នៅយ៉ាងណា?*

អ្នកនយោបាយ ទស្សនៈវិទូ អ្នកវិទ្យាសាស្ត្រ អ្នកចិត្តសាស្ត្រ និងអ្នកសង្គមវិទូសម័យទំនើបតែងតែផ្ដល់ ដំណោះស្រាយសំរាប់បញ្ហាផ្សេងៗនៅក្នុងពិភពលោករបស់យើង។ ប៉ុន្តែដំណោះស្រាយដែលមិនទទួលយកសេចក្ដីពិតអំពី បាបនេះគឺមិនអាចទទួលយកបានទេ ពីព្រោះដំណោះស្រាយទាំងនោះមិនទាន់បានយល់អំពីជម្រៅនៃបញ្ហារបស់មនុស្សទេ។ មនុស្សមិនអាចដោះស្រាយ បញ្ហាដ៏ធ្ងន់ធ្ងរនៃបាប ដែលមាននៅក្នុងខ្លួនយើងម្នាក់ៗនោះឡើយ។ មានតែព្រះទេដែលអាចដោះស្រាយបាន។

> នេះជាបញ្ហាដែលប្រឈមមុខនឹងយើង។ នៅក្នុងខ្លួនយើងមានអំណាចអាក្រក់និងខ្លាំងពូកែដែលហៅថា “បាប” ដែលផ្ដាច់យើងចេញពីព្រះហើយនាំយើងឲ្យស្អប់ទ្រង់ ហើយវាបង្ខូចកិត្តិយសរបស់យើង ក៏នាំយើងឲ្យមានឥរិយាបថគួរឲ្យខ្ពើមរអើម។ វាជាការចំកួតក្នុងការគិតអំពីបញ្ហាទាំងនេះហើយគ្រាន់តែពិភាក្សាខាងផ្នែកទ្រឹស្ដីប៉ុណ្ណោះ។ វាជាការខុសក្នុងការគិតថាយើងមិនមានបញ្ហានេះ។ មានតែនៅពេលយើងប្រឈមនឹងសេចក្ដីពិត ហើយដឹងអំពីលក្ខណៈពិតរបស់បញ្ហាទេទើបយើងនឹងមើលឃើញថាមានតែអំណាចមួយដែលអាចដោះស្រាយ វាបាន គឺអំណាចរបស់ព្រះ។[១៧]

**យើងពឹងលើសេចក្ដីមេត្តាករុណារបស់ព្រះទាំងស្រុង។**

នៅពេលយើង ដឹងថាសេចក្ដីត្រូវការរបស់យើងធំក្រៃលែង នោះយើងគួរតែឲ្យតំលៃសេចក្ដីស្រលាញ់ សេចក្ដីមេត្តាករុណា និងព្រះគុណដ៏មានសិរីល្អ អស្ចារ្យរបស់ព្រះដែលរំដោះយើងចេញពី បាប។ ការនេះបង្ខាប់ឲ្យយើងថ្វាយបង្គំព្រះសំរាប់សេចក្ដីសង្គ្រោះដ៏អស្ចារ្យនេះ។ សមត្ថភាពរបស់ បាបក្នុងការបំផ្លាញគឺធំធេងណាស់។ យើងត្រូវតែញញើតនិងស្អប់ខ្ពើមវា។ បាបពិតជាធំធេងខ្លាំងណាស់ដែលមានតែការសុគតរបស់ព្រះរាជបុត្រានៃព្រះប៉ុណ្ណោះដែលអាចរំដោះយើងចេញពីវាបាន។ ដូច្នេះ ចូរយើងចងចាំៈ

> ដ្បិតក្រោយដែលយើងបានទទួលស្គាល់សេចក្ដីពិតហើយបើយើងធ្វើបាបស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណាសំរាប់នឹងលោះបាបទៀតទេ មានតែរង់ចាំដោយស្ញែងខ្លាចចំពោះសេចក្ដីជំនុំជំរះ និងសេចក្ដីសហ័សនៃភ្លើងដែលរៀបនឹងឆេះដល់អស់ទាំងពួកទាស់ទទឹងផងប៉ុណ្ណោះ ឯអ្នកណាដែលក្បត់ក្រិត្យវិន័យលោកម៉ូសេ នោះបានត្រូវស្លាប់ឥតគេប្រណី ដោយសេចក្ដីបន្ទាល់របស់មនុស្ស ២ ឬ ៣ នាក់ ចុះតើអ្នករាល់គ្នាស្មានថា គេគួរមានទោសជាធ្ងន់ជាងយ៉ាងណាទៅ ដែលគេជាន់ឈ្លីព្រះរាជបុត្រានៃព្រះ ទាំងរាប់ព្រះលោហិតនៃសេចក្ដីសញ្ញា ដែលបានញែកគេចេញជាបរិសុទ្ធ ទុកដូចជារបស់ប្រើធម្មតា ហើយត្មះតិះដៀលដល់ព្រះវិញ្ញាណដ៏មានព្រះគុណផងនោះ ដ្បិតយើងស្គាល់ព្រះអង្គដែលទ្រង់មានបន្ទូលថា “សេចក្ដីសងសឹកជារបស់ផងអញ អញនឹងសងគេ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់” ហើយ ១ ទៀតថា “ព្រះអម្ចាស់ទ្រង់នឹងជំនុំជំរះរាស្ត្រទ្រង់” រីឯការដែលធ្លាក់ទៅក្នុងកណ្ដាប់ព្រះហស្តនៃព្រះដ៏មានព្រះជន្មរស់នៅ នោះគួរស្ញែងខ្លាចណាស់។ (ហេព្រើរ ១០:២៦-៣១)។

## *កំណត់*


១. Matthew White, “Deaths by Mass Unpleasantness: Estimated Totals for the Entire 20th Century,” http://users.erols.com/mwhite28/warstat8.htm.

២. Christopher J. H. Wright, The Mission of God: Unlocking the Bible’s Grand Narrative (Downers Grove, IL: InterVarsity, 2006), 433–34.

៣. Quoted in Henri Blocher, Original Sin: Illuminating the Riddle, New Studies in Biblical Theology 5 (Downers Grove, IL: InterVarsity, 1997), 61.

៤. Quoted in Harold G. Coward, The Perfectibility of Human Nature in Eastern and Western Thought (Albany, NY: State University of New York Press, 2008), 83.

៥. Jonathan Edwards, The Complete Works of Jonathan Edwards (Carlisle, PA, Banner of Truth, repr. 1995), 1:145.

៦. Quoted in Blocher, Original Sin, 83–84.

៧. Herman Bavinck, Our Reasonable Faith (Grand Rapids, MI: Eerdmans, 1956), 221.

៨. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤).

៩. John Murray, Collected Writings of John Murray: Lectures in Systematic Theology (Carlisle, PA, Banner of Truth, 1978), 2:69.

១0. Herman Bavinck, Reformed Dogmatics: Sin and Salvation in Christ (Grand Rapids, MI: Baker Academic, 2004), 3:64–65.

១១. See Robert L. Reymond, A New Systematic Theology of the Christian Faith, 2nd ed. (Nashville, TN: Nelson, 1998), 436–39.

១២. The Gospel Coalition Confessional Statement.

១៣. Bavinck, Our Reasonable Faith, 229.

១៤. R. L. Dabney, Systematic Theology (Carlisle, PA: Banner of Truth, 1985), 323.

១៥. Ibid., 313, 324.

១៦. Bavinck, Our Reasonable Faith, 248.

១៧. D. Martyn Lloyd-Jones, The Plight of Man and the Power of God (Ada, MI: Baker, 1982), 57.